រដ្ឋសភា
ចូល លេខ ២៨៥៧ ថ្ងៃទី ២៦/១០ ឆ្នាំ ២០១៧ ម៉ោង ១៥:៣០ បញ្ជូនទៅ

# ព្រះរាជក្រម

នស/រកម/១០១៧/០១២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩១/០៣១/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្ដីពី

# វិសោធនកម្មច្បាប់ស្ដីពី

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

# ឃុំ សង្កាត់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.**

មាត្រា ២០ និងមាត្រា ២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២០.ថ្មី**

ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ ។

គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយនៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ។

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយ ដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់នីតិវិធីឡើងវិញ ដើម្បីសម្របសម្រួលជាមួយគណបក្សនយោបាយទាំងនោះ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ តាមជំហានទាំងឡាយដូចខាងក្រោម ៖

ជំហានទីមួយ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈទៅតាមករណីដូចខាងក្រោម៖

ទី១.ករណីដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះ